Disability Rights California

*California's protection & advocacy system*

# *សលាកបត្រព័ត៌មានស្តីពីការរើសអើងលើពិការភាព៖ បុគ្គលិករដ្ឋ និងបុគ្គលិករដ្ឋាភិបាលក្នុងមូលដ្ឋាន*

*ខែមិថុនា ឆ្នាំ2018 ការបោះពុម្ពផ្សាយ #F119.06 - Cambodian*

## បុគ្គលិករដ្ឋ និងបុគ្គលិករដ្ឋាភិបាលក្នុងមូលដ្ឋាន

បុគ្គលិករដ្ឋ និងបុគ្គលិករដ្ឋាភិបាលក្នុងមូលដ្ឋាន ត្រូវទទួលបានការការពារដោយច្បាប់របស់រដ្ឋនិងសហព័ន្ធចំពោះការរើសអើងលើពិការភាព។ មាត្រា I នៃច្បាប់សហព័ន្ធស្តីពីពលរដ្ឋអាមេរិកាំងដែលមានពិការភាព (ADA) ហាមឃាត់ការរើសអើងលើពិការភាពនៅក្នុងការងារ។ មាត្រា II នៃច្បាប់ ADA ហាមឃាត់រដ្ឋនិងរដ្ឋាភិបាលក្នុងមូលដ្ឋានចំពោះការរើសអើងលើពិការភាព។ មាត្រា 504 នៃច្បាប់ស្តារនីតិសម្បទា ក៏ហាមឃាត់ផងដែរចំពោះការរើសអើងលើពិការភាពប្រឆាំងនឹងអង្គភាពរដ្ឋាភិបាលដែលទទួលមូលនិធិពីសហព័ន្ធ។

ច្បាប់ស្តីពីលំនៅដ្ឋាននិងការងារស្មើភាពគ្នារបស់រដ្ឋកាលីហ្វញ៉ា (California Fair Employment and Housing Act (FEHA)) ផ្តល់នូវការការពារស្រដៀងគ្នានេះដែរ។ ការបំពានណាមួយចំពោះច្បាប់ ADA ឬមាត្រា 504 ក៏ចាត់ទុកជាបំពានលើច្បាប់រដ្ឋផងដែរ។ ក៏ប៉ុន្តែ ក្នុងកាលៈទេសៈមួយចំនួន ច្បាប់រដ្ឋអាចផ្តល់នូវការការពារកម្រិតខ្ពស់ជាងច្បាប់សហព័ន្ធ។

ការរើសអើងរួមមាន ការប្រព្រឹត្តិពុំស្មើភាព ការសងសឹក និងបំពារបំពានចំពោះនិយោជិត និងអ្នកដាក់ពាក្យសុំការងារដែលមានពិការភាព។ វាក៏រួមបញ្ចូលផងដែរនូវការខកខានក្នុងការផ្តល់ជូននូវការកែសម្រួលដែលសមស្របចំពោះការអនុវត្តការងារ គោលនយោបាយ ឬលក្ខខណ្ឌកន្លែងការងាររបស់និយោជក ដើម្បីផ្តល់ដំណោះស្រាយលើបញ្ហាពិការភាពរបស់និយោជិត ឬអ្នកដាក់ពាក្យសុំការងារ។ ដំណោះស្រាយ ឬការកែសម្រួលណាមួយអាចមានលក្ខណៈសមស្របឬអត់នោះ គឺវាអាស្រ័យលើស្ថានភាពជាក់លាក់ និងប្រភេទនៃការងារពាក់ព័ន្ធ។ ដំណោះស្រាយនិងការកែសម្រួលសមស្រប ពុំអាចដាក់បន្ទុកធ្ងន់ធ្ងរ (ការលំបាកខ្លាំង ឬការចំណាយច្រើន) ដល់និយោជកនោះទេ។ គំរូលិខិតដើម្បីស្នើសុំដំណោះស្រាយសមស្រប និងគំរូលិខិតគាំទ្រពីអ្នកជំនាញព្យាបាល គឺនៅខាងក្រោម។

ខាងក្រោមនេះ គឺជាធនធាននានាដើម្បីសិក្សាស្វែងយល់បន្ថែមអំពីការរើសអើងលើពិការភាព និងដំណោះស្រាយសមស្របនៅក្នុងការងារ៖

- គេហទំព័រគណៈកម្មការសម្រាប់ឱកាសស្មើភាពគ្នារបស់សហរដ្ឋអាមេរិក (U.S. Equal Opportunity Commission (EEOC))៖ http://www.eeoc.gov/laws/types/disability.cfm
- គេហទំព័រនាយកដ្ឋានលំនៅដ្ឋាននិងការងារស្មើភាពគ្នារដ្ឋកាលីហ្វញ៉ា (California Department of Fair Employment and Housing)៖ http://www.dfeh.ca.gov/Employment
- គេហទំព័របណ្ដាញដំណោះស្រាយការងារ (Job Accommodations Network) សម្រាប់ព័ត៌មានអំពីដំណោះស្រាយក្នុងការងារ៖ http://askjan.org
- ជំនួយផ្លូវច្បាប់នៅគេហទំព័រការងារ សម្រាប់ធនធាននានា និងតំណាងផ្នែកផ្លូវច្បាប់៖ https://legalaidatwork.org/

## ស្វ័យតស៊ូមតិ

ប្រសិនបើអ្នកជឿជាក់ថា អ្នកត្រូវបានគេរើសអើង អ្នកអាចទាក់ទងអ្នកសម្របសម្រួលផ្នែកច្បាប់ ADA នៃទីភ្នាក់ងាររបស់អ្នក ឬការិយាល័យ EEO ឬដាក់បណ្ដឹងរដ្ឋបាលនៅកម្រិតរដ្ឋនិងកម្រិតសហព័ន្ធ។

ទីភ្នាក់ងាររដ្ឋនីមួយៗ ត្រូវមានការិយាល័យឱកាសការងារស្មើភាពគ្នា (Equal Employment Opportunity Office (EEO))។ EEO ទទួលខុសត្រូវក្នុងការដោះស្រាយការទាមទារចំពោះការរើសអើង ឬសំណើសុំសម្រាប់ដំណោះស្រាយសមស្របណាមួយនៅក្នុងទីភ្នាក់ងារនោះ។ ដើម្បីស្វែងរកព័ត៌មានសម្រាប់ទំនាក់ទំនងមន្ត្រីផ្នែកការងារស្មើភាពគ្នានៃទីភ្នាក់ងាររបស់អ្នក សូមចូលទៅកាន់៖

http://www.calhr.ca.gov/state-hr-professionals/Pages/ocr-description.aspx

រដ្ឋាភិបាលក្នុងមូលដ្ឋានដែលមានបុគ្គលិកពី 50 នាក់ ឬច្រើនជាងនេះ ត្រូវធ្វើការតែងតាំងនិយោជិតយ៉ាងតិចម្នាក់ដើម្បីធ្វើការសម្របសម្រួលបណ្ដឹង ADA។ អ្នកសម្របសម្រួល ADA ធ្វើការជាមួយអង្គភាពរដ្ឋាភិបាលដើម្បីធ្វើការងារអប់រំដល់ផ្នែកនានាអំពីសិទ្ធិរបស់និយោជិតដែលមានពិការភាព និងធ្វើការស៊ើបអង្កេតលើបណ្ដឹងនៃការមិនអនុវត្តតាមច្បាប់ ADA និងច្បាប់រដ្ឋ។ អ្នកអាចស្វែងរកព័ត៌មានសម្រាប់ទំនាក់ទំនងអ្នកសម្របសម្រួលច្បាប់ ADA ក្នុងមូលដ្ឋាននៅគេហទំព័រទីក្រុង ឬខោនធីបាន។

អ្នកក៏អាចដាក់បណ្ដឹងរដ្ឋបាលជាមួយនាយកដ្ឋានលំនៅដ្ឋាននិងការងារស្មើភាពគ្នារដ្ឋកាលីហ្វញ៉ា (DFEH) ឬក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក (U.S. Department of Justice)។

ពាក្យបណ្ដឹងអាចប្ដឹងបាននៅ DFEH ក្នុងរយៈពេលមួយឆ្នាំគិតចាប់ពីថ្ងៃដែលមានការរើសអើងនេះ។ គេហទំព័រ DFEH មានព័ត៌មានស្ដីពីការដាក់បណ្ដឹង និងការបន្តបណ្ដឹងស្ដីពីការរើសអើង។ https://www.dfeh.ca.gov/filing-a-complaint-online/។

អ្នកត្រូវដាក់បណ្ដឹងរដ្ឋបាលមួយច្បាប់ និងត្រូវមាន "លិខិតបញ្ជាក់សិទ្ធិដាក់ពាក្យប្ដឹង" ពី DFEH មុនពេលដែលអ្នកអាចដាក់បណ្ដឹងសម្រាប់ករណីនៃការរើសអើងលើពិការភាពនៅតុលាការរបស់រដ្ឋបាន។

ស្ថិតក្រោមកិច្ចព្រមព្រៀងចែករំលែកការងារជាមួយ EEOC ក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក (DOJ) គឺជាទីភ្នាក់ងារសហព័ន្ធដែលមានទំនួលខុសត្រូវចម្បងក្នុងការស៊ើបអង្កេតលើ

បណ្ដឹងស្ដីពីការរើសអើងការងារប្រឆាំងនឹងនិយោជិតក្នុងមាត្រា II។ និយោជិតនៃអង្គភាពរដ្ឋាភិបាល ដែលទទួលមូលនិធិសហព័ន្ធ គប្បីដាក់បណ្ដឹងលើការរើសអើងក្រោមមាត្រា 504 ជូនដល់ទីភ្នាក់ងារសហព័ន្ធដែលផ្ដល់នូវមូលនិធិនោះ។ បណ្ដឹងត្រូវប្ដឹងជាមួយ DOJ ឬទីភ្នាក់ងារសហព័ន្ធដែលពាក់ព័ន្ធក្នុងរយៈពេល 180 ថ្ងៃបន្ទាប់មានការរើសអើងនោះ។

ដើម្បីដាក់បណ្ដឹង ADA នៅ DOJ សូមប្រើទម្រង់ពាក្យបណ្ដឹងតាមប្រព័ន្ធអនឡាញដែលមាននៅគេហទំព័រ ADA របស់ក្រសួងនៅ www.ada.gov។

ពាក្យបណ្ដឹងអាចផ្ញើតាមប្រៃសណីយ៍ទៅកាន់ផ្នែកសិទ្ធិជនពិការ (Disability Rights Section) នៅ៖

U.S. Department of Justice
950 Pennsylvania Avenue, N.W.
Civil Rights Division
Disability Rights Section
Washington, D.C. 20530

តុលាការបានកំណត់ថា ដោយមានភាពខុសគ្នាពីចំណាត់ការដែលធ្វើឡើងប្រឆាំងនឹងនិយោជកឯកជនស្ថិតក្រោមច្បាប់ ADA T.I  ដូចនេះ វាមិនចាំបាច់ត្រូវមានលិខិតបញ្ជាក់សិទ្ធិដាក់ពាក្យប្ដឹងពី DOJ នៅមុនពេលដាក់ពាក្យបណ្ដឹងទៅតុលាការតាមមាត្រា II ឬផ្នែក 504 នោះទេ។ តុលាការទាំងនោះ បានថែងថា នៅពេលដែលបទដ្ឋានផ្លូវច្បាប់នៃមាត្រា I អនុវត្តចំពោះមាត្រា II និងមាត្រា 504 នៃការទាមទារបណ្ដឹងលើការរើសអើងក្នុងការងារ លក្ខខណ្ឌតម្រូវនៃនីតិវិធីនៃមាត្រា I ពុំត្រូវបានអនុវត្តនោះទេ។ បណ្ដឹងស្ថិតក្រោមមាត្រា 504 ឬ T.II  ត្រូវដាក់ប្ដឹងនៅក្នុងរយៈពេលមួយឆ្នាំបន្ទាប់ពីកាលបរិច្ឆេទនៃការរើសអើង។

## បណ្ដឹងវិវាទ

ការបំពានច្បាប់ដែលបានពិភាក្សាខាងលើ អាចត្រូវបានអនុវត្តតាមរយៈបណ្ដឹងឯកជន។ សូមមេត្តាជ្រាបថា អាជ្ញាយុកាលកំណត់ពេលវេលាសម្រាប់ការដាក់បណ្ដឹងវិវាទនេះ ហេតុនេះ អ្នកអាចបាត់បង់ឱកាសក្នុងការទាមទារ ប្រសិនបើអ្នកពុំបានចាត់វិធានការក្នុងពេលនៃអាជ្ញាយុកាលដែលមានជាធរមាននេះ។ អភ័យឯកសិទ្ធិនៃអំណាចគ្រប់គ្រងក៏អាចកំណត់លើដំណោះស្រាយដែលអាចមានផ្ដល់ជូនពីអង្គភាពរដ្ឋាភិបាលផងដែរ។ ប្រសិនបើអ្នកចង់បន្តដាក់បណ្ដឹងវិវាទ អ្នកគប្បីប្រឹក្សាយោបល់ជាមួយមេធាវីណាម្នាក់ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

# គំរូលិខិតដើម្បីស្នើសុំដំណោះស្រាយសមស្របណាមួយ

[កាលបរិច្ឆេទ]

គោរពជូន [និយោជក]៖

ខ្ញុំបាទ/នាងខ្ញុំសរសេរលិខិតនេះដើម្បីស្នើសុំដំណោះស្រាយសមស្របណាមួយសម្រាប់បញ្ហាពិការភាពរបស់ខ្ញុំ។ ខ្ញុំបាទ/នាងខ្ញុំ [ជានិយោជិតនៅ/កំពុងដាក់ពាក្យសុំធ្វើការនៅ] [អង្គភាពសាធារណៈ]។ ដោយសារបញ្ហាពិការភាពរបស់ខ្ញុំ ខ្ញុំត្រូវការដំណោះស្រាយដូចតទៅនេះ៖ [ចំណុចនៃដំណោះស្រាយ]។ [គ្រូពេទ្យ/គ្រូពេទ្យផ្នែកសរសៃប្រសាទ/អ្នកចិត្តសាស្ត្រ/គ្រូពេទ្យព្យាបាល/បុគ្គលិកសង្គមកិច្ច/គ្រូពេទ្យព្យាបាលសប្បទាវិជ្ជាជីវៈ/បុគ្គលដទៃផ្សេងទៀត (សូមរៀបរាប់)] របស់ខ្ញុំ បានកំណត់ថា ដំណោះស្រាយ/ការកែសម្រួលទាំងអស់នេះ មានសារៈសំខាន់ចាំបាច់ដើម្បីជួយដោះស្រាយបញ្ហាពិការភាពរបស់ខ្ញុំ។ សូមពិនិត្យមើលលិខិតភ្ជាប់ជូនពី [ឈ្មោះវេជ្ជបណ្ឌិត ឬអ្នកជំនាញ]។

ច្បាប់សហព័ន្ធនិងច្បាប់រដ្ឋ តម្រូវឲ្យនិយោជកផ្តល់ដំណោះស្រាយជូនដល់និយោជិតនិងអ្នកដាក់ពាក្យសុំដែលមានពិការភាព។ សូមឆ្លើយតបចំពោះសំណើនេះត្រឹម [កាលបរិច្ឆេទ]។ សូមទាក់ទងមកកាន់ខ្ញុំតាមរយៈលេខ [លេខទូរសព្ទរបស់អ្នក និង/ឬអាសយដ្ឋានអ៊ីម៉ែល] ប្រសិនបើអ្នកមានសំណួរណាមួយ។ សូមអរគុណ។

ដោយសេចក្តីគោរពអំពីខ្ញុំ

[ឈ្មោះរបស់អ្នក]
[អាសយដ្ឋានរបស់អ្នក]

# គំរូលិខិតគាំទ្រ

[កាលបរិច្ឆេទ]

គោរពជូន [អង្គភាពសាធារណៈ]៖

ខ្ញុំគឺជា [គ្រូពេទ្យ/គ្រូពេទ្យផ្នែកសរសៃប្រសាទ/អ្នកចិត្តសាស្ត្រ/គ្រូពេទ្យព្យាបាល/បុគ្គលិកសង្គមកិច្ច/គ្រូពេទ្យព្យាបាលសម្បទាវិជ្ជាជីវៈ] សម្រាប់ [ឈ្មោះ] ហើយខ្ញុំបានដឹងអំពីស្ថានភាពរបស់គាត់។ គាត់មានពិការភាព ដែលបង្កឲ្យមានបញ្ហាមិនអាចបំពេញមុខងារមួយចំនួនបាន។ បញ្ហាទាំងនេះ រួមមាន [រៀបរាប់ពីបញ្ហាមិនអាចបំពេញមុខងារបានដែលតម្រូវឲ្យមានដំណោះស្រាយដែលបានស្នើសុំនេះ]។

[ដំណោះស្រាយដែលបានស្នើសុំ] គឺមានភាពចាំបាច់សម្រាប់ [ឈ្មោះ] ដើម្បី [ធ្វើការងារនៅ/ដាក់ពាក្យសុំការងារនៅ] [និយោជក]។ [រៀបរាប់ថាតើដំណោះស្រាយនេះ នឹងជួយឬគាំទ្រដល់បុគ្គលនោះយ៉ាងដូចម្ដេចខ្លះ]។

សូមអរគុណសម្រាប់ការផ្តល់ដំណោះស្រាយសមស្របសម្រាប់ [ឈ្មោះ]។

ដោយសេចក្តីគោរពអំពីខ្ញុំ
[ឈ្មោះនិងមុខតំណែង]

យើងចង់ស្តាប់មតិយោបល់របស់លោកអ្នក!
សូមបំពេញការស្ទង់មតិដូចខាងក្រោមនេះអំពីឯកសារបោះពុម្ពផ្សាយរបស់យើងខ្ញុំ និង
សូមឲ្យយើងដឹងថាតើសកម្មភាពដែលយើងកំពុងធ្វើនេះមានលក្ខណៈដូចម្តេច!
[ធ្វើការស្ទង់មតិ]
ដើម្បីទទួលបានជំនួយផ្នែកច្បាប់សូមហៅទៅលេខ 800-776-5746 ឬបំពេញ សំណុំបែបបទស្នើសុំជំនួយ។ សម្រាប់គោលបំណងផ្សេងទៀត សូមហៅទូរសព្ទទៅកាន់ 916-504-5800 (ភាគខាងជើងរដ្ឋកាលីហ្វញ៉ា) 213-213-8000 ( ភាគខាងត្បូងរដ្ឋកាលីហ្វញ៉ា)។
អង្គការសិទ្ធិជនពិការរដ្ឋកាលីហ្វញ៉ា (Disability Rights California) ត្រូវបានផ្តល់មូលនិធិ
ដោយប្រភពខុសៗគ្នាសម្រាប់បញ្ជីពេញលេញនៃអ្នកផ្តល់មូលនិធិសូមចូលទៅកាន់
http://www.disabilityrightsca.org/Documents/ ListofGrantsAndContracts.html។